ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៤៦ អនក្រ.បក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការចម្រុះអភិវឌ្ឍន៍តំបន់ព្រំដែនកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការចម្រុះអភិវឌ្ឍន៍តំបន់ព្រំដែនកម្ពុជា-ថៃ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ហោ ណាំហុង | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | ឯកឧត្តម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម វ៉ា គឹមហុង | ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក |
| ៤- | ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |

៥- ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៦- ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៧- ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៨- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

៩- ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១០- ឯកឧត្តមនាយឧត្តមសេនីយ៍ នាង ផាត រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១១- ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋលេខាធិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១២- ឯកឧត្តម ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា សមាជិក

១៣- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកោះកុង ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ សមាជិក

១៤- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លេខាធិការប្រតិបត្តិ។

**ប្រការ២.-**

គណៈកម្មាធិការនេះមានភារកិច្ចធ្វើការអភិវឌ្ឍសេដ្ឋកិច្ចតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

**ប្រការ៣.-**

សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹង សេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាល នៃគណៈអភិបាលខេត្តកោះកុង ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ